# បើខ្ញុំជឿលើព្រះយេស៊ូវ តើមានផលប្រយោជន៍អ្វីខ្លះដល់រូបខ្ញុំ?

នេះគឺជាសំណួរមួយ ដែលមនុស្សភាគច្រើនតែងតែសួរទៅកាន់អ្នកជឿលើ ព្រះយេស៊ូវ។ មានមូលហេតុជាច្រើន ដែលមនុស្សបានសួរសំណួរនេះ។ យើង នឹងស្វែងរកមូលហេតុខ្លះនៅក្នុងកូនសៀវភៅនេះនៅពេលក្រោយ តែឥឡូវនេះ យើងនឹងឆ្លើយសំណួរខាងលើជាមុនសិន។

ហេតុអ្វីបានជាមានអ្នកកាន់សាសនាលោកិយផ្សេងៗ បែរជាស្វែងយល់ និងជឿលើព្រះយេស៊ូវ ? តើព្រះយេស៊ូវបានសន្យាអ្វីខ្លះចំពោះអ្នកដែលកែប្រែចិត្ត ហើយជឿលើទ្រង់ ? មានការសន្យាជាច្រើន ដែលព្រះអង្គបានប្រទានចំពោះ អ្នកដែលជឿលើទ្រង់ពិតប្រាកដ និងអស់ពីចិត្ត។ នៅក្នុងកូនសៀវភៅនេះ យើងនឹងគិតពិចារណាលើការសន្យាដ៏អស្ចារ្យតែពីរប៉ុណ្ណោះ។ការសន្យាទាំងពីរនេះ ត្រូវបានស្វែងរកនៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូវចំពោះសិស្សម្នាក់របស់ទ្រង់ ឈ្មោះប៉ុល។

*គម្ពីរ<u>កិច្ចការ ២៦:១៨</u> ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឲ្យបានបែរចេញពីសេចក្តីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឲ្យគេបាន<u>រួចពីបាប</u> ហើយបាន<u>ទទួលមរតក</u> ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារ សេចក្តីជំនឿជឿដល់ខ្ញុំ។*

## ១. សេចក្តីសន្យាទី១: ការរួចពីបាប

ព្រះជាម្ចាស់បានសន្យាថា ទ្រង់នឹងប្រោសយើងឲ្យរួចផុតពីជំងឺដ៏ធ្ងន់ធ្ងរ គឺជាជំងឺ នៃអំពើបាបនៅក្នុងចិត្តរបស់យើង ដែលធ្វើឲ្យយើងស្លាប់ ហើយនិងដាច់ចេញពី ព្រះអង្គ។ នេះគឺជាការសន្យាមួយដ៏អស្ចារ្យជាងគេបំផុត។

<u>ហេតុអ្វីបានជាយើងទាំងអស់គ្នាត្រូវទទួលការលើកលែងទោសបាបរបស់យើង?</u>

យើងបានប្រព្រឹត្តអំពើបាបជាច្រើនប្រឆាំងនឹងព្រះដ៏ពិតតែមួយ ដែលបានបង្កើត យើងមក។ យើងរាល់គ្នាបានបះបោរប្រឆាំងនឹងព្រះ ហើយបានរមិលគុណ ចំពោះទ្រង់សម្រាប់អ្វីៗទាំងអស់ ដែលព្រះបានប្រទានឲ្យយើងនៅលើផែនដីនេះ។យើងបានធ្វើរូបចម្លាក់ជាច្រើន ហើយបានថ្វាយបង្គំរូបចម្លាក់ទាំងនោះ។ អំពើបាបផ្សេងទៀតដែលយើងរាល់គ្នាបានប្រព្រឹត្តគឺ ការភូតកុហក ការមិនគោរព ប្រតិបត្តិឪពុកម្តាយ ការលួចរបស់របរអ្នកដទៃ ការមានចិត្តខឹងនិងស្អប់ អ្នកជិតខាង ហើយនិងការលោភលន់ចង់បានទ្រព្យសម្បត្តិអ្នកដទៃ។ល។ ស្ទើរតែគ្រប់ពេលវេលា យើងមិនបានស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីដួងចិត្ត របស់យើងនោះទេ ហើយក៏មិនបានស្រឡាញ់អ្នកដទៃដូចជាខ្លួនយើងដែរ។



ដោយសារព្រះមានលក្ខណៈល្អបរិសុទ្ធ ទ្រង់មិនអាចបំភ្លេចនូវអំពើបាបរបស់យើង បានឡើយ។ តាមការពិត ព្រះពេញទៅដេ
សេចក្តីក្រោធចំពោះអំពើបាប របស់យើង។ រាល់អំពើបាបរបស់យើងត្រូវតែមានការសងថ្លៃ។ បើសិនយើង ចង់សងថ្លៃរាល់អ
បាបរបស់យើង នោះយើងនឹងត្រូវសងថ្លៃបាបរបស់យើង នៅក្នុងបឹងភ្លើងជារៀងរហូត ត្បិតអំពើបាបរបស់យើងអាក្រក់ហ
ប្រមាណ នឹងអាចសងរួច។ អំពើបាបរបស់យើងគឺជាបញ្ហាធ្ងន់ធ្ងរ ហើយយើងទាំងអស់គ្នា ត្រូវការរួចពីបាបយ៉ាងក្រៃលែង។

*គម្ពីរ<u>វិវរណៈ ២១:៨</u> តែត្រង់ពួកខ្លាច ពួកមិនជឿ ពួកគួរខ្ពើម ពួកកាប់សម្លាប់គេ ពួកកំផិត ពួកមន្តអាគម ពួកថ្វាយបង្គំរូបព្រះ ហើយគ្រប់
មនុស្សកំភូត គេនឹងមានចំណែកនៅក្នុងបឹង ដែលឆេះជាភ្លើងនិងស្ពាន់ធ័រ គឺជាសេចក្តីស្លាប់ទី២វិញ។*

<u>តើនរណាអាចលើកលែងទោសអំពើបាបរបស់យើងបាន?</u>

មានតែព្រះជាម្ចាស់តែប៉ុណ្ណោះ (អ្នកដែលយើងរាល់គ្នាបានបះបោរប្រឆាំងធ្វើបាប) អាចលើកលែងទោសនូវអំពើបាបរបស់យ
បាន។ គឺព្រះជាម្ចាស់នោះឯង ដែលបានសំរេចព្រះទ័យយាងចុះពីឋានសួគ៌ មកគង់នៅលើផែនដីនេះ (ចាប់កំណើតជាមនុ
ដើម្បីធ្វើជាផ្លូវតែមួយសម្រាប់យើងទាំងអស់គ្នា អាចទទួលការលើកលែងទោសបាបរបស់យើងបាន។ នៅពេលដែលព្រះ
បានយាងចុះមកនៅលើផែនដីនេះ ទ្រង់បានយកព្រះនាមពិសេសមួយគឺ *យេស៊ូវ* ដែលមានន័យថា *ព្រះអង្គសង្គ្រោះ*។
យេស៊ូវបានបំពេញគ្រប់ច្បាប់នៃព្រះ ជំនួសយើង ព្រោះយើងរាល់គ្នាធ្វើមិនបាន។ ព្រះអង្គមិនដែលប្រព្រឹត្ត
អំពើបាបណាមួយឡើយ។ ទ្រង់មិនសមនឹងបានទទួលរងនូវការធ្វើគត់ឡើយ តែទ្រង់ជ្រើសរើស (ដោយសេចក្តីស្រឡាញ់រ
ទ្រង់) យកការលះបង់ជីវិតជំនួស យើងរាល់គ្នា។ ព្រះយេស៊ូវបានទទួលយកនូវរាល់អំពើបាបរបស់យើងទាំងអស់គ្នា ដាក់លើ
ទ្រង់ ពេលដែលទ្រង់នៅលើឈើឆ្កាង។ ទ្រង់បានទទួលនូវបទពិសោធ នៃការឈឺចាប់ដ៏លើសលប់ ទាំងរូបកាយ ទាំងវិញ្ញា
ជំនួសយើងគ្រប់ៗគ្នា។ សេចក្តីក្រោធនៃព្រះចំពោះអំពើបាបរបស់យើងបានចាក់ស្រោចមកលើទ្រង់។ នេះគឺជាការសំដែងដ៏
លែងនៃសេចក្តីស្រឡាញ់នៅក្នុងប្រវត្តិលោកិយ៖ គឺការសុខចិត្តស្លាប់សម្រាប់សត្រូវផ្ទាល់ខ្លួន ! យើងត្រូវតែមកគាល់ព្រះ
ព្រះហឫទ័យ និងគំរោងការរបស់ព្រះអង្គ មិនមែនតាមផ្លូវដែលយើង ឬមនុស្សឯទៀតបានបង្កើតនោះឡើយ។ ព្រះយេស៊ូវ
ផ្លូវតែមួយគត់ ដែលព្រះជាម្ចាស់បានប្រទានឲ្យមនុស្សយើង។

*គម្ពីរ<u>អេសាយ ៥៣:៥-៦</u> តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការ
ផ្ចាល ដែលនាំឲ្យយើង បានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គ
យើងទាំងអស់គ្នាបានទាសចេញដូចជាចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ហើយព្រះយេហូវ៉ាបានទំលាក់ អំពើទុច្ចរិតរ
យើងទាំងអស់គ្នាទៅលើទ្រង់។*

## ២. សេចក្តីសន្យាទី២: ការទទួលមរតកនៃព្រះ

ព្រះមិនមែនគ្រាន់តែប្រោសយើងពីជំងឺនៃអំពើបាបដោយការលើកលែងទោស នូវ អំពើបាបរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែទ្រ
បានប្រទានឲ្យយើងនូវទ្រព្យសម្បត្តិ ដ៏មានតម្លៃខ្ពស់ជាងគេបំផុតគឺ ព្រះវិញ្ញាណបរិសុទ្ធនៃព្រះនឹងយាងមកសណ្ឋិតនៅ ជា
យើង។ នេះជាការសន្យាដ៏អស្ចារ្យ ! ព្រះវិញ្ញាណបរិសុទ្ធត្រូវបានប្រទាន ឲ្យយើងដូចជាប្រាក់កក់ដំបូង ជាភស្តុតាងបង្ហាញ
ថា មានមរតក បន្ថែមទៀតនឹងមកពេលក្រោយ។ ព្រះវិញ្ញាណនៃព្រះនឹងយាងមកគង់នៅក្នុង ពួកអ្នកជឿលើទ្រង់ គឺក្នុងខ
ពេលដែលយើងទើបតែទទួលជឿលើព្រះយេស៊ូវ ដើម្បីទទួលសេចក្តីសង្គ្រោះ។ អស់អ្នកណាដែលជឿលើព្រះយេស៊ូវមិន
ខ្លាច វិញ្ញាណអាក្រក់ ឬអារក្សបីសាចណាឡើយ ត្បិតព្រះវិញ្ញាណដែលមានអំណាច លើសលប់នោះ រស់នៅក្នុងខ្លួនអ្នក
នោះ!

*គម្ពីរយ៉ូហានទី១ ៤:៤ ពួកកូនតូចៗអើយ អ្នករាល់គ្នាមកពីព្រះ ហើយក៏ឈ្នះវិញ្ញាណ ទាំងនោះដែរ ពីព្រោះព្រះដែលគង់ក្នុងអ្នករាល់គ្នា នោះទ្រង់ធំជាងអានោះ ដែលនៅក្នុងលោកិយផង។*

<u>តើការគង់នៅនៃព្រះវិញ្ញាណបរិសុទ្ធនោះ មានផលប្រយោជន៍អ្វីខ្លះចំពោះយើង នៅពេលឥឡូវនេះ?</u>

១. **ព្រះវិញ្ញាណបរិសុទ្ធប្រទានឲ្យយើងនូវជីវិតអស់កល្បជានិច្ច នៅពេលឥឡូវនេះ!**

ព្រះយេស៊ូវបានប្រទានដល់យើងនូវជីវិតរបស់ទ្រង់ ដើម្បីនៅពេលណា ដែលយើងស្លាប់ទៅ យើងអាចត្រឡប់ទៅរស់នៅជាមួយទ្រង់នៅឋានសួគ៌បាន។ រូបកាយរបស់យើងនឹងនៅតែស្លាប់ ប៉ុន្តែព្រលឹងវិញ្ញាណរបស់យើងនឹងមិនដែល ស្លាប់ឡើយ។ អស់អ្នកដែលបានកែប្រែចិត្ត ហើយជឿលើព្រះយេស៊ូវ មិនត្រូវខ្លាច សេចក្ដីស្លាប់ឡើយ ត្បិតព្រះជាម្ចាស់បានប្រទានឲ្យយើងនូវជីវិតអស់កល្បជានិច្ច។

*គម្ពីរ<u>យ៉ូហាន ៥:២៤</u> ប្រាកដមែន ខ្ញុំ(ព្រះយេស៊ូវ)ប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណា ដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គដែលចាត់ខ្ញុំមក អ្នកនោះមានជីវិតដ៏នៅ អស់កល្បជានិច្ច ហើយមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្តីស្លាប់ ទៅដល់ជីវិតវិញ។*

២. **ព្រះវិញ្ញាណបរិសុទ្ធផ្លាស់ប្តូរចិត្ត និងការប្រព្រឹត្តរបស់យើង នៅពេលឥឡូវនេះ!**

ព្រះវិញ្ញាណបរិសុទ្ធមកគង់នៅជាមួយយើង ដើម្បីបំផ្លាស់ចិត្តគំនិត របស់យើង ហើយនាំយើងឲ្យរស់នៅក្នុងសេរីភាពពីអំណាចនៃអំពើបាប។ សាសនារបស់លោកិយផ្សេងៗ បានបង្រៀនយើងយ៉ាងត្រឹមត្រូវអំពីការចាំបាច់ នៃការកែប្រែចេញពីផ្លូវបាប ក៏ប៉ុន្តែសាសនាមិនអាចជួយយើងឲ្យផ្លាស់ប្រែបាន នោះទេ។ សាសនាអាចអប់រំមនុស្សឲ្យធ្វើការល្អបាន ក៏ប៉ុន្តែវាគ្មានអំណាច ផ្លាស់ប្តូរជីវិតរបស់យើងបានឡើយ។ យើងត្រូវការការផ្លាស់ប្តូរ មិនមែនការអប់រំ! យើងរាល់គ្នាខ្វះសមត្ថភាពគាប់ព្រះទ័យព្រះ។ យើងទាំងអស់គ្នាត្រូវការចិត្តថ្មី និងជីវិតថ្មី ដែលមានតែព្រះទេដែលអាចប្រទានឲ្យយើងបាន។ នៅពេលដែល យើងមានព្រះវិញ្ញាណនៃព្រះក្នុងខ្លួនយើង ទ្រង់បង្រៀនយើងឲ្យស្គាល់ព្រះ ហើយមានសេចក្តីប្រកបជាមួយនឹងទ្រង់នៅពេលឥឡូវនេះ។ ព្រះអង្គបង្រៀន យើងឲ្យចេះលះបង់អំពើបាបដែលយើងធ្លាប់ប្រព្រឹត្ត ហើយនាំឲ្យយើងស្គាល់ សេចក្តីអំណរ និងសេចក្តីសុខសាន្តដ៏ពិតរបស់ទ្រង់។ អ្នកណាដែលពិតជាប្រែចិត្ត ហើយជឿពិតប្រាកដលើព្រះយេស៊ូវនឹងមានការផ្លាស់ប្តូរក្នុងជីវិត ព្រោះព្រះវិញ្ញាណនៃព្រះ ដែលគង់នៅជាមួយពួកគាត់ ទ្រង់នឹងជួយអ្នកនោះ ឲ្យផ្លាស់ប្តូរដោយព្រះគុណរបស់ព្រះអង្គ។

*គម្ពីរ<u>កូរិនថុសទី២ ៥:១៧</u> បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថា បានកើតជាថ្មីហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅមើល គ្រប់ទាំងអស់ បានត្រឡប់ជាថ្មីវិញ។*

<u>តើអ្វីទៅជាមរតកនៅពេលអនាគត?</u>

មរតកនៅពេលអនាគតរបស់យើង គឺនៅឯឋានសួគ៌ មិនអាចពិពណ៌នា បានឡើយ! យើងនឹងឃើញព្រះដ៏ពិត ហើយនិងថ្វាយបង្គំទ្រង់ ព្រមទាំងរីករាយ ជាមួយនឹងទ្រង់រហូតតទៅ។ ទ្រង់នឹងប្រទានដល់យើងនូវរូបកាយមួយថ្មី ដែលគ្មានអំពើបាប។ ព្រះអង្គនឹងបង្កើតឋានសួគ៌ និងផែនដីថ្មីសម្រាប់យើង ដែលជាកន្លែងគ្មានការឈឺចាប់ គ្មានការរងទុក្ខវេទនា គ្មានអំពើបាប ឬសេចក្តីស្លាប់ឡើយ។ យើងនឹងបានជៀសផុតពីទុក្ខវេទនា ដែលមកពីបណ្តាសារ នៃអំពើបាបរបស់យើងជារៀងរហូត!

*គម្ពីរ<u>ពេត្រុសទី១ ១:៣-៤</u> សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើតយើងឡើងជាថ្មី តាមសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឲ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ ហើយឲ្យយើងបានមរតក ដែលមិនចេះពុករលួយ ក៏ឥតសៅហ្មង ហើយមិនដែលស្រពោនឡើយ ជាមរតក ដែលបំរុងទុកឲ្យយើងរាល់គ្នានៅឋានសួគ៌។*

## មូលហេតុដែលមនុស្សសួរសំណួរនេះ៖ បើខ្ញុំជឿលើព្រះយេស៊ូវ តើមានផលប្រយោជន៍អ្វីខ្លះដល់រូបខ្ញុំ?

ដូចជាយើងបានប្រាប់ជាដំបូងកូនសៀវភៅនេះ មានមូលហេតុជាច្រើន ដែលមនុស្សបានសួរសំណួរខាងលើនេះ។ អ្នកខ្លះមានចម្ងល់អំពីជំនឿលើព្រះ ហើយចង់ដឹងពីមូលហេតុត្រឹមត្រូវ ដែលមនុស្សគួរតែជឿលើព្រះយេស៊ូវ។ អ្នកផ្សេងទៀតមិនសួរសំណួរនេះទេ ព្រោះពួកគេមិនចាប់អារម្មណ៍ចំពោះព្រះ និងព្រះបន្ទូលរបស់ព្រះអង្គ តែដោយសារពួកគេចង់ដឹងពីអ្វីៗ ដែលក្រុមអង្គការឬបរទេស នឹងផ្តល់ឲ្យពួកគេ បើសិនពួកគេចាប់ផ្តើមរៀនព្រះគម្ពីរ ឬជឿលើ ព្រះយេស៊ូវ។ ក្នុងចំណោមពួកគេទាំងនោះ អ្នកខ្លះចាប់អារម្មណ៍រៀន ភាសាបរទេស ឬចង់លេងកីឡាជាមួយអ្នកជឿ។ អ្នកខ្លះទៀតចង់បានការងារធ្វើ ឬចង់បានលាភសក្ការៈផ្សេងៗ។ ប្រសិនបើគ្មានការទាំងអស់នេះ អញ្ចឹង ពួកគេ មិនចាប់អារម្មណ៍រៀន និងដើរតាមព្រះយេស៊ូវនោះទេ។

អ្នកផ្សេងទៀតមានប្រាថ្នាដើរតាមព្រះយេស៊ូវ ព្រោះពួកគេបានឮគ្រូបង្រៀនថា៖ បើសិនជាអ្នកជឿលើព្រះយេស៊ូវ ព្រះអង្គនឹងប្រទានពរដល់អ្នកនូវសុខភាពល្អ និងមានទ្រព្យសម្បត្តិច្រើនក្នុងជីវិតនេះ។ មានក្រុមខ្លះដែលតាំងខ្លួនថាជា អ្នកជឿលើព្រះយេស៊ូវ បង្រៀនតាមបែបខាងលើនេះ។ បើលោកអ្នកស្រាវជ្រាវ ព្រះគម្ពីរទាំងមូលនឹងឃើញការសន្យាទាំងអស់របស់ព្រះអង្គចំពោះរាស្ត្ររបស់ទ្រង់ នៅក្នុងប្រវត្តិនេះ លោកអ្នកនឹងមិនឃើញការសន្យាណាមួយ ដែលព្រះអង្គនឹង ប្រទានឲ្យមនុស្សយ៉ាងពិតប្រាកដនូវសុខភាពល្អខាងរូបកាយ និងទ្រព្យសម្បត្តិ ច្រើនក្នុងជីវិតនេះទេ។ អស់អ្នកណាដែលបង្រៀនការខុសឆ្គងទាំងអស់នេះ គឺមិនមែនប្រាប់ការពិតឡើយ។ ហេតុអ្វី ? ព្រោះយើងមិនអាចគេចផុតពី បណ្តាសារនៃអំពើបាប ក្នុងពេលដែលយើងរស់នៅលើផែនដីនេះបានឡើយ។ យើងទាំងអស់គ្នាត្រូវតែស្លាប់ខាងរូបកាយ ទទួលបទពិសោធន៍នៃជម្ងឺ ហើយនិងជួបប្រទះការលំបាកផ្សេងៗទៀតជាពិតប្រាកដ។

## ការដាស់តឿនចុងក្រោយ

សេចក្តីសន្យាទាំងពីរ ដែលយើងបានរៀបរាប់ក្នុងកូនសៀវភៅនេះ (ការរួចពីបាប ហើយនិងការទទួលមរតកនៃព្រះ) គឺជារបស់ទ្រព្យដែលលោកិយនេះ ហើយនិង សាសនាក្នុងលោកិយ មិនអាចជូនដល់មនុស្សបានឡើយ។ ការសន្យាទាំងពីរនេះ មានតម្លៃខ្ពស់ជាងអ្វីៗទាំងអស់នៅលើផែនដីនេះ ដូចជាលុយកាក់ អំណាច កិត្តិយស ឬការសប្បាយ ។ល។ ព្រះយេស៊ូវបានរំលឹកយើងថា ទ្រព្យសម្បត្តិ នៅក្នុងលោកិយនេះនឹងបាត់អស់ទៅ។ អញ្ចឹង យើងគួរតែប្រមូលទ្រព្យសម្បត្តិ ដែលបិតថេរជារៀងរហូតវិញ។

*គម្ពីរ<u>ម៉ាថាយ ៦:១៩-២១</u> កុំឲ្យប្រមូលទ្រព្យសម្បត្តិទុកសំរាប់ខ្លួននៅផែនដី ជាកន្លែង ដែលមានកន្លាត និងច្រែះស៊ីបំផ្លាញ ហើយចោរទំលុះប្លន់នោះឡើយ ត្រូវប្រមូល ទ្រព្យសម្បត្តិទុកសំរាប់ខ្លួននៅឯឋានសួគ៌វិញ ដែលជាកន្លែងគ្មានកន្លាត ឬច្រែះស៊ីបំផ្លាញ ឡើយ ក៏គ្មានចោរទំលុះ ឬប្លន់ផង ពីព្រោះសម្បត្តិទ្រព្យរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ។*
*គម្ពីរយ៉ូហានទី១ ២:១៧ ឯលោកិយនេះ និងសេចក្តីប៉ងប្រាថ្នារបស់វា នោះកំពុង កន្លងទៅ តែអ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ នោះនឹងនៅជាប់ អស់កល្បជានិច្ចវិញ។*

សូមឲ្យអស់លោកអ្នកដែលបានអានកូនសៀវភៅនេះ បានទទួលព្រះពរ ហើយនិងមានប្រាជ្ញាពីព្រះអម្ចាស់!

និពន្ធដោយ: លោក ស៊ីវ៉ែត គ្រីស នៅខេត្តប៉ៃលិន
ខែ ១១ ឆ្នាំ ២០១១
ទូរស័ព្ទលេខ: ០១២ ៧៩ ២៥ ២៩